N.21
08.6.02

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ព្រះរាជក្រឹត្យ


២៧-៥-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៥០២/១៤៥ ស្តីពីការតែងតាំង ឯកឧត្តម **ណូរីតាដា ម៉ូរីតា** ( NORITADA MORITA )ជាទីប្រឹក្សាកិត្តិយសជាន់ខ្ពស់នៃឧត្តមក្រុមប្រឹក្សា សេដ្ឋកិច្ចជាតិ ១៤៥២

២៧-៥-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៥០២/១៤៦ ស្តីពីការតែងតាំង ឯកឧត្តម **ណាម៉ាណាថាន់ ណាតារ៉ាចាន់** (NAMANATHAN NATARAJAN )ជាទីប្រឹក្សាកិត្តិយសជាន់ខ្ពស់នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ១៤៥៣

០១-៦-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៥០២/១៤៧ ស្តីពីការតែងតាំង ឯកឧត្តម **អ៊ឹម ខេង** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ១៤៥៤


## II – រាជរដ្ឋាភិបាល

### ១_ អនុក្រឹត្យ


០៤-៦-២០០២ - អនុក្រឹត្យ លេខ ២៧៦ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៥៥

០៤-៦-២០០២ - អនុក្រឹត្យ លេខ ២៧៧ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៥៧

០៤-៦-២០០២ - អនុក្រឹត្យ លេខ ២៧៨ អនក្រ. តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៤៥៨

០៤-៦-២០០២ - អនុក្រឹត្យ លេខ ២៧៩ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៥៩

០៤-៦-២០០២ - អនុក្រឹត្យ លេខ ២៨០ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៦០

០៤-៦-២០០២ - អនុក្រឹត្យ លេខ ២៨១ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៦២


### ២_ សេចក្តីសំរេច


០៧-៦-២០០២ - សេចក្តីសំរេចលេខ ៣១ សសរ ស្តីពីការបង្កើតគណៈប្រតិភូអន្តរក្រសួងដើម្បីពិភាក្សាការងារជាមួយភាគីថៃស្តីពីការបើកច្រកទ្វារព្រំដែនអូរស្មាច់ ១៤៦៣


### ៣_ សារាចរ


០៧-៦-២០០២ - សារាចរលេខ ០១ សរ ស្តីពីការរៀបចំ ឆ្លើយតប គ្រោះមហន្តរាយ ១៤៦៥


## III-ការងារបណ្តាក្រសួង

### ១_ ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៦-៦-២០០២ - ប្រកាសលេខ ១៥៩ MoC/M 2002 ស្តីពីលទ្ធផល នៃ ការដេញថ្លៃកូតាសំរាប់នាំចេញសំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០២ ១៤៧០

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១៤៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១: តែងតាំងឯកឧត្តម **ណូរីតាដា ម៉ូរីតា** ( NORITADA MORITA ) ជាទីប្រឹក្សាកិត្តិយសជាន់ខ្ពស់ នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។

មាត្រា ២: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ: ១៣៥៤.៧

ដើម្បីចម្លងចែក

៣៧៤-០២.០៥.០០១៥៥

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០០២

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាង ធាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១៤៦

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១: តែងតាំងលោកឧត្តម **រ៉ាម៉ាណាថាន់ ណាតារ៉ាចាន់** ( RAMANATHAN NATARAJAN ) ជាទីប្រឹក្សាកិត្តិយសជាន់ខ្ពស់ នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។

មាត្រា ២: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ: ១៣៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ តាន់

៣.ល.០៥.០៥.០០១៥៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៤៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** តែងតាំងឯកឧត្តម **អ៊ីវ ខេង** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលការងារខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខៈ ១៣៦ ច.ល

ដើម្បីចម្លងចែក

៣៧ល. ០៤-០៦-០០១៥៧

រាជធានីភ្នំពេញ.ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សៅ ឌី តាន់**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៧៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ០៨ រូប ដែលបានបរិច្ចាគធនធានជួយកសាង សមិទ្ធផលនានាក្នុងវត្តអង្គស្វែង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមាននាមខាងក្រោម ÷

**ក ‒ មេដាយមាសស្ថាបនាជាតិ :**

១ - ព្រះតេជគុណ **ទឹម សារឹម** ថវិកា ៨០.០០០ USD

២ - ឯកឧត្តម **សូ ផន** ថវិកា ១១.៩៣៨ USD

៣ - លោក **ឯក សេដ្ឋា** នៅសហរដ្ឋអាមេរិក ថវិកា ១៥.៣៥២ USD

៤ - លោក **ទ៉ែត នយ** ថវិកា ១៣.០០០ USD

**ខ ‒ មេដាយប្រាក់ស្ថាបនាជាតិ :**

- លោក **មុំ ម៉ិន** ថវិកា ៥.១០០ USD

**គ ‒ មេដាយសំរិទ្ធស្ថាបនាជាតិ :**

១ - ឧកញ៉ា **ហេង សារ៉ាត** ថវិកា ៣.១០០ USD

២ - លោក **ឡូច ម៉េង** ថវិកា ៣.៣០០ USD

៣ - លោក **ម៊ុត ជន** ថវិកា ៣.២៥០ USD

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៧៧.អនក្រ.ស.ត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **អូសាវ៉ៃណ មីអិកុ** អ្នកសំរបសំរួលការងារអង្គការ **JHP** ជប៉ុន ដែលបានជួយកសាង និង ជួសជុលអគារសិក្សា នៅសាលាបឋមសិក្សាត្រពាំងអំពិល ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ ៦៣.៦៨២ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...២៧៨...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រីជាន់ខ្ពស់ ០៣ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ដូចមាននាមខាងក្រោម ÷

១-ឯកឧត្តម **ជា សុខុម** អគ្គលេខាធិការរងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

២-ឯកឧត្តម **ជា គាន** អគ្គលេខាធិការរងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

៣-ឯកឧត្តម **ញ៉ៀម វ៉ាលី** អគ្គលេខាធិការរងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៧៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិរវជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ០៥ រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកាជួយកសាងស្ពានបេតុង ០១ កន្លែង ប្រវែង ៨៥ ម៉ែត្រ ទទឹង ០៦ ម៉ែត្រ នៅឃុំកំពង់រាប ស្រុកព្រែកប្បាស ខេត្តតាកែវ ដូចមាននាមខាងក្រោមនេះ ÷

| | | | | | |
|---|---|---|---|---|---|
| ១- ព្រះតេជគុណ | **ទីង** | **ទន់** | វត្តស្វាយពពែ (ភ្នំពេញ) | ថវិកា | ១២.០០០ USD |
| ២- ព្រះតេជគុណ | **សៅ** | **សន** | វត្តស្វាយពពែ (ភ្នំពេញ) | ថវិកា | ១៣.០០០ USD |
| ៣- លោក | **ទិន** | **វ៉ុន** | ស្រុកកោះធំ ខេត្តកណ្តាល | ថវិកា | ១២.០០០ USD |
| ៤- សពលោក | **រស់** | **ចាន់** | ស្រុកព្រែកប្បាស | ថវិកា | ១១.២០០ USD |
| ៥- លោក | **ពេជ** | **សុខ** | ស្រុកព្រែកប្បាស | ថវិកា | ១០.៥០០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ១៨៤ ៧

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧៨០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ០៨ រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលនានា នៅក្នុងវត្តស្វាយអណ្តែត ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ដូចមាននាមខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **ហម** | **សារាវុធ** | ថវិកា ១១.០៦០ USD |
| ២-លោកស្រី | **គង់** | **មុំ** | ថវិកា ១១.៥០០ USD |

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **គង់** | **ធូ** | ថវិកា ៤.១២៦ USD |
| ២-ព្រះតេជគុណ | **ខាន់** | **ឡឹង** | ថវិកា ២.៧៦៣ USD |
| ៣-អ្នកស្រី | **នន់** | **តានី** | ថវិកា ១.៧០០ USD |
| ៤-លោកយាយ | **ណៃ** | | ថវិកា ២.៧០៧ USD |
| ៥-លោកតា | **ញ៉ឹប** | **ថ្វន** | ថវិកា ១.០០៥ USD |
| ៦-លោក | **អ៊ឹម** | **ផង់** | ថវិកា ១.៤១៨ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៥១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ហាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ហាបនាជាតិ** ជូនលោក **ឡាច ទូច** ដែលបានលះបង់ធនធានផ្ទាល់ខ្លួន អស់ទឹកប្រាក់ចំនួន ៩៧.៣៩៥.០០០ រៀល និង ៤.៣០០ ដុល្លារអាមេរិក សំរាប់បំរើដល់វិស័យព្រះពុទ្ធសាសនា និង សង្គម ស្ថិតនៅក្នុងឃុំព្រែកទន្លាប់ ឃុំកំពង់ភ្នំ និង ឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្តាល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា និង អភិបាល - ខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៦ អនក្រ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈប្រតិភូអន្តរក្រសួង

## ដើម្បីពិភាក្សាការងារជាមួយភាគីថៃ ស្តីពីការបើកច្រកទ្វារព្រំដែនអូរស្មាច់

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**ប្រការ១:** បង្កើតគណៈប្រតិភូអន្តរក្រសួងមួយ ដើម្បីពិភាក្សាការងារជាមួយភាគីថៃ ស្តីពីការបើកច្រកទ្វារព្រំដែន អូរស្មាច់ (កម្ពុជា)- ចុងជាំ (ថៃ)ដែលមានសមាសភាព ដូចខាងក្រោមនេះ :

១-ឯកឧត្តម **ឡុង វិសាលោ** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធាន

២-ឯកឧត្តម **វ៉ា គឹមហុង** ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន សមាជិក

៣-ឯកឧត្តម **សូរ ទិចន័រ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ សមាជិក

៤-ឯកឧត្តមអភិបាលខេត្តឧត្តរមានជ័យ សមាជិក

៥-ឯកឧត្តម **ខៀវ មុត** អគ្គនាយកបច្ចេកទេស ក្រសួងបរិស្ថាន សមាជិក

៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈុំ សុជាត** នាយកទីចាត់ការការងារព្រំដែន ក្រសួងការពារជាតិ សមាជិក

SSC.III.decision

៧-លោក **លឹម សំកុល** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨- លោក វរៈសេនីយ៍ឯក **ប្រាក់ ភារណារ៉ា** អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ក្រសួងមហាផ្ទៃ សមាជិក

**ប្រការ២:** គណៈប្រតិភូអន្តរក្រសួងដើម្បីពិភាក្សាការងារជាមួយភាគីថៃ ដែលមានបេសកកម្ម និងភារកិច្ច ដូចតទៅ :

១- ចូលរួមចរចា និងពិភាក្សាជាមួយភាគីថៃ លើបញ្ហាជុំវិញការបើកច្រកទ្វារព្រំដែន អូរស្មាច់ ( កម្ពុជា ) - ចុងជាំ ( ថៃ ) ដែលរួមមាន ការបង្កើតកាស៊ីណូ ការកំណត់ខ្សែព្រំដែន ការការពារបរិស្ថាន ការគ្រប់គ្រងរដ្ឋបាលនៅច្រកទ្វារព្រំដែន ការអនុវត្ត និងលើបញ្ហាធ្វើវិសោធនកម្ម លើកិច្ចព្រមព្រៀងឆ្លងដែននៃប្រទេសទាំងពីរ កម្ពុជា - ថៃ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៧ ហើយនៅពេលនោះ កិច្ចព្រមព្រៀងពុំទាន់បានកំណត់ នូវច្រកទ្វារព្រំដែនអោយបានទូលំទូលាយ នូវអាទិភាពនៃការឆ្លងកាត់ព្រំដែនរបស់ប្រជាជននៅតំបន់ព្រំដែន នៃប្រទេសទាំងពីរ និង ការកំណត់ស្រុកទាំងឡាយ របស់ភាគីទាំងពីរដែលនៅជាប់ព្រំដែនជាដើម ។

២- ត្រៀម និងរៀបចំរាល់ឯកសារពាក់ព័ន្ធ សំរាប់ធ្វើការចរចាជាមួយភាគីថៃ ។

**ប្រការ៣:** សមាជិកគណៈប្រតិភូ ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន ។

**ប្រការ៤:** គណៈប្រតិភូអន្តរក្រសួងនេះ មានលេខាធិការដ្ឋាននៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយអាចប្រើប្រាស់ត្រារបស់ក្រសួងនេះ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

**ប្រការ៥:** គណៈប្រតិភូអន្តរក្រសួងនេះ នឹងអស់សុពលភាព នៅពេលបញ្ចប់បេសកកម្មរបស់ខ្លួន ដូចមានចែងក្នុងប្រការ២ ។

**ប្រការ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៦
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ :...០១...សរ

# សារាចរ
# ស្តីពី
# ការត្រៀមរៀបចំ ឆ្លើយតប គ្រោះមហន្តរាយ

គ្រោះមហន្តរាយតែងតែកើតមានជាញឹកញាប់ នៅព្រះរាជាណាចក្រកម្ពុជា ដែលបង្កឡើងដោយធម្មជាតិផង និងបង្កឡើងដោយមនុស្សផង។ គ្រោះមហន្តរាយដោយធម្មជាតិគឺមាន ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ .... ហើយគ្រោះមហន្តរាយ ដែលបង្កឡើងដោយមនុស្សមាន អគ្គិភ័យ គ្រោះថ្នាក់ចរាចរជាដើម ។ គ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួត គឺជាបញ្ហាចំបងដែលជះឥទ្ធិពលយ៉ាងខ្លាំង ដល់ផលិតកម្មស្បៀងអាហារ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ហើយទឹកជំនន់បានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់ជីវិតមនុស្ស ផ្ទះសម្បែង ស្រែចំការ ដំណាំរួមផ្សំ។ វត្តអារាម សាលារៀន មន្ទីរពេទ្យ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាច្រើនក៏ត្រូវបំផ្លិចបំផ្លាញ ដោយទឹកជំនន់ដែរ ។

ប្រឈមមុខនឹងគ្រោះមហន្តរាយខាងលើ រាជរដ្ឋាភិបាល តែងតែយកចិត្តទុកដាក់យ៉ាងខ្លាំង និងបានដាក់ចេញនូវ សារាចរលេខ ០២ សរ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការត្រៀម កាត់បន្ថយ និង គ្រប់គ្រងគ្រោះមហន្តរាយ ហើយឆ្លងតាមស្ថានភាពទឹកជំនន់ឆ្នាំ ២០០១ ឃើញថា ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋបានចូលរួមអនុវត្តតាមគោលការណ៍ ដែលបានដាក់ចេញនៅក្នុង សារាចរខាងលើ ទទួលបានលទ្ធផល ល្អប្រសើរ ។

ឈរលើមូលដ្ឋាននៃការអនុវត្តន៍ ឆ្លើយតបពេលទឹកជំនន់ ឆ្នាំ២០០១ និងផ្អែកលើលទ្ធផល ការងារគ្រប់គ្រងគ្រោះមហន្តរាយដែលមានពីមុនមក រាជរដ្ឋាភិបាល សូមដាក់ចេញនូវគោលការណ៍សំរាប់អនុវត្តមួយចំនួន

បន្ថែមលើសារាចរលេខ ០២ សរ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០១ សំរាប់ ត្រៀមរៀបចំឆ្លើយតប គ្រោះមហន្តរាយ នៅព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

១- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវធ្វើការសំរបសំរួល ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធលើការងារគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមានូវមុខសញ្ញា គ្រោះថ្នាក់ដែលបង្កឱ្យមានគ្រោះមហន្តរាយនានា ហើយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះ ត្រូវបញ្ជូនពត៌មានពិតប្រាកដទាន់ពេលវេលា អំពីផលប៉ះពាល់ និងការខូចខាតដោយគ្រោះមហន្តរាយមក គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ពេលមានគ្រោះមហន្តរាយកើតឡើង នៅតំបន់ណាមួយ ។

២- ក្រសួង ស្ថាប័ន ពាក់ព័ន្ធដែលមានការងារជាប់ទាក់ទងទៅនឹងគ្រោះមហន្តរាយនានា ត្រូវរៀបចំបង្កើតក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ នៅតាមក្រសួង ស្ថាប័នរបស់ខ្លួន ដូចមានចែងក្នុងជំពូក ៥ មាត្រា ១៧ នៃអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០០២ ដោយចាត់តាំងមន្ត្រី ធ្វើការអចិន្ត្រៃយ៍នៅក្រុមការងារនេះ ជាខ្សែរយៈជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីភាពងាយស្រួលក្នុងការទំនាក់ទំនងការងារ ។

៣- ក្រសួងការពារជាតិ អគ្គមេបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវធ្វើការពិភាក្សាកំណត់ អំពីការពង្រាយផ្ទះចល័តនៅតាមតំបន់ ធ្លាប់មានបញ្ហាគ្រោះមហន្តរាយកើតឡើង ហើយកងយោធពលខេមរភូមិន្ទ គឺជាកំលាំងអន្តរាគមន៍ស្នូលក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះដោយគ្រោះមហន្តរាយនានា និង ទទួលខុសត្រូវក្នុងការរៀបចំតំលើង និងរុះរើផ្ទះចល័តយកមកគ្រប់គ្រង ថែរក្សា ទុកដាក់អោយបានល្អ ។

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបន្តអនុវត្តការត្រៀមថវិកា នៅក្នុងជំពូកចំណាយពុំបានគ្រោងទុកសំរាប់ដោះស្រាយនូវតំរូវការជាបន្ទាន់ទាំងឡាយ ដែលកើតមានដោយគ្រោះមហន្តរាយនានា និងជួយផ្តល់ថវិកាដល់កិច្ចប្រតិបត្តិការ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

៥- ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ត្រូវសហការ ជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអាជ្ញាធរដែនដី ដើម្បីធ្វើការជ្រើសរើសដីបំរុងទុករបស់រដ្ឋ សំរាប់ធ្វើជាទីទួល

សុវត្ថិភាព ។ ក្នុងករណីមានការសង្ស័យ អំពីគ្រាប់មិនទាន់ផ្ទុះ ឬ មីននោះ ត្រូវសហការជាមួយក្រុមដោះមីន **CMAC** ឬកងវិស្វកម្ម ដើម្បីរាវរក និងបោសសំអាតចេញ ។

៦- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវបន្តសហការអនុវត្តការងារ ជាមួយក្រុម សំរបសំរួលគ្រោះអាសន្ន ដែលមានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, សមាគមជាតិកាកបាទក្រហមកម្ពុជា, សហព័ន្ធអន្តរជាតិកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម, ក្រុមគ្រប់គ្រងគ្រោះមហន្តរាយសហប្រជាជាតិ និងមានអនុក្រុម៤ ជាជំនួយការ គឺអនុក្រុមជួយសង្គ្រោះគ្រោះអាសន្នដឹកនាំដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង សមាគមជាតិកាកបាទក្រហមកម្ពុជា, អនុក្រុមសន្តិសុខ ស្បៀង និងហេដ្ឋារចនាសម្ព័ន្ធ ដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសាធារណការ និងដឹកជញ្ជូន, អនុក្រុមសុខភាពដឹកនាំដោយ ក្រសួង សុខាភិបាល, អនុក្រុមអនាម័យ និងទឹកស្អាតដឹកនាំដោយក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីពិនិត្យវាយតំលៃផលប៉ះពាល់ ការខូចខាត សេចក្តីត្រូវការ និងលើកវិធានការស្តារឡើងវិញ ។

៧- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវរៀបចំក្រុមវាយតំលៃការខូចខាត និងតំរូវការពេលមានគ្រោះមហន្តរាយកើតឡើង ។ ក្រុមនេះត្រូវមានការចូលរួមពីតំណាងក្រសួងពាក់ព័ន្ធគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដើម្បីសំរបសំរួលជាមួយ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ សំរាប់ធ្វើការប៉ាន់ប្រមាណផលប៉ះពាល់ដែលកើតមានដោយគ្រោះមហន្តរាយ និងបញ្ជាក់នូវចំណុចមួយចំនួន :

ក- ចរិតលក្ខណៈ និង វិសាលភាព នៃគ្រោះមហន្តរាយ

ខ- កត្តាដែលបណ្តាលអោយខូចខាត និងបង្ហាញពីការគំរាមកំហែង បន្ទាប់បន្សំ

គ- តំរូវការរបស់ប្រជាជនរងគ្រោះ

ឃ- សមត្ថភាព ឆ្លើយតបបាន ដែលមានប្រភពនៅមូលដ្ឋាន

ង- ជំរើសសំរាប់ការជួយសង្គ្រោះ ការកសាងឡើងវិញរយៈពេលវែង និង ការអភិវឌ្ឍន៍

ច- តំរូវការជំនួយអន្តរជាតិ

៨- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវរៀបចំគំរោង ប្រើប្រាស់បច្ចេកវិទ្យា ទូរគមនាគមន៍នៅទីកន្លែងដែលមានការខ្វះខាត សំរាប់បញ្ជូន និងទទួលពត៌មានពីគណៈកម្មាធិការជាតិ

គ្រប់គ្រងគ្រោះមហន្តរាយ ជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ឱ្យបានឆាប់ទាន់សភាពការណ៍ ព្រមទាំងផ្សព្វផ្សាយ ការអនុវត្តន៍ផែនការត្រៀមបង្ការគ្រោះមហន្តរាយ ។

៩- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌត្រូវលើកកំពស់ការងារសហប្រតិបត្តិការ និងសំរបសំរួលការងារជាមួយគ្រប់ថ្នាក់ គ្រប់ផ្នែកក្រសួង មន្ទីរពាក់ព័ន្ធ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការងារជំលៀស ការការពារសន្តិសុខ សណ្តាប់ធ្នាប់នៅទីទួលសុវត្ថិភាព ការផ្តល់ជំនួយស្បៀងអាហារ ទឹក អនាម័យ ជំនួយសុខភាព និងជំនួយចាំបាច់ដទៃទៀត សំរាប់ជួយដល់ពលរដ្ឋរងគ្រោះដោយគ្រោះមហន្តរាយនានា ។

១០- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ សហការ និងសំរបសំរួលការងារឱ្យបានល្អ ជាមួយភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការ ក្រៅរដ្ឋាភិបាលដែលមានទីតាំងនៅមូលដ្ឋានរបស់ខ្លួន ។ នៅពេលមានគ្រោះមហន្តរាយកើតឡើង ត្រូវរួមគ្នាធ្វើការវាយតំលៃការខូចខាត សេចក្តីត្រូវការ និងរាយការណ៍មកគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

១១- ថ្នាក់ឃុំ-សង្កាត់ ត្រូវបង្កើតក្រុមគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ-សង្កាត់ ដែលមាន មេឃុំ ឬ ចៅសង្កាត់ជាប្រធាន និងមេភូមិគ្រប់ភូមិ ជាសមាជិក ដើម្បីរៀបចំការទទួលខុសត្រូវ លើការងារត្រៀមបង្ការ ឆ្លើយតប សង្គ្រោះបន្ទាន់ ពេលមានគ្រោះមហន្តរាយ និងការធ្វើអោយមានប្រក្រតីភាពឡើងវិញក្រោយពេលគ្រោះមហន្តរាយ ។

១២- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ត្រូវយកចិត្តទុកដាក់ពង្រឹងក្រុមគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ដែលបានបង្កើតឡើងតាមរយៈការអប់រំ បណ្តុះបណ្តាលមុខជំនាញ ដើម្បីអោយមានសមត្ថភាពបំពេញការងារជួយដល់សហគមន៍ដែលងាយរងគ្រោះ ។

១៣- ក្រុមគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ត្រូវផ្តល់ពត៌មាន អំពីហេតុការណ៍ គ្រោះមហន្តរាយបំរុងនឹងកើតឡើង ហើយនឹងបានកើតឡើងមកឱ្យគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ ហើយស្រុក-ខ័ណ្ឌត្រូវរាយការណ៍តាមលំដាប់ថ្នាក់ជាបន្ទាន់ ឱ្យបានឆាប់បំផុតមក

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីមានវិធានការដោះស្រាយ និងលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និងអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ជាពិសេស គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ត្រូវយកចិត្តទុកដាក់ធ្វើការផ្សព្វផ្សាយ និងចាត់ចែងអនុវត្តអោយសំរេចបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន - ស្ថាប័ន
-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-សាលាខេត្ត-ក្រុង
-គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង
-កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. 7៤៨ MoC / M 2002

ភ្នំពេញ,ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពីលទ្ធផល នៃ ការដេញថ្លៃកូតាសំរាប់នាំចេញ សំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០២

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម ។
- យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ឡែន សរសៃ សិប្បនិម្មិតធ្វើពីដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និង សរសៃល្បាយសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ និងការបន្តសុពលភាពនៃកិច្ចព្រមព្រៀងនេះ តាមអនុស្សារណៈនៃការយោគយល់គ្នាទៅវិញទៅមករវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១ ។
- យោងតាមកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៩ ។
- យោងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ ១៤២ MoC/M2002 ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការដាក់ អោយដេញថ្លៃ លើកូតាសំលៀកបំពាក់ដែលត្រូវនាំចេញទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០២ ។
- យោងតាមការចាំបាច់នៃការងារ ។

/\

# សម្រេច

**ប្រការ ១ :** ទទួលស្គាល់លទ្ធផលនៃការដេញថ្លៃកូតា តាមប្រភេទសំលៀកបំពាក់នីមួយ ៗ សំរាប់ការនាំចេញទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០២ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ A ។

**ប្រការ ២ :** ក្រុមហ៊ុនទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ A នៃប្រការ ១ ត្រូវបង់ប្រាក់បន្ថែម ៩០% អោយបានមុនថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០២ ។ ការខកខានបង់ នឹងអាចនាំអោយមានការរឹបអូសប្រាក់កក់ ១០% និងការបង្វិលកូតាដែលដេញបានយកទៅទុកដេញថ្លៃ នៅលើកក្រោយវិញ ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការមិនអនុញ្ញាតអោយក្រុមហ៊ុននោះចូលរួមក្នុងការដេញថ្លៃកូតាលើកក្រោយៗទៀត ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

<u>ចំលងជូន :</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
  " ដើម្បីជ្រាបជាពត៌មាន "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*File : Quota Tender Result, June 06, 2002*

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

**ANNEX - A**

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE

1:03 PM, 06/06/2002

MINISTRY OF COMMERCE

TENDER of QUOTA

## TENDER of QUOTA
## June 6,2002

| ID | COMPANY NAME | 334/634 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 15,664 | $3.00 | | | |
| 1 | Hechter Cambodia Garment Ltd | 8,000 | $9.00 | $72,000.00 | $7,200.00 | $64,800.00 |
| 2 | QMI Industrial Co LTd | 6,000 | $9.00 | $54,000.00 | $5,400.00 | $48,600.00 |
| 3 | Ocean Garment Co Ltd | 1,664 | $8.60 | $14,310.40 | $1,431.04 | $12,879.36 |
| | **TOTAL** | 15,664 | | $140,310.40 | $14,031.04 | $126,279.36 |

| ID | COMPANY NAME | 335/635 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 8,328 | $3.00 | | | |
| 1 | Suit Way & Larissaca Fashion Factory Ltd | ~~5,000~~ | ~~$16.40~~ | ~~$82,000.00~~ | ~~$8,200.00~~ | ~~$73,800.00~~ |
| 2 | Goldfame Enterprises Knitting Co Ltd | 1,000 | $14.00 | $14,000.00 | $1,400.00 | $12,600.00 |
| 3 | QMI Industrial Co LTd | 2,328 | $13.20 | $30,729.60 | $3,072.96 | $27,656.64 |
| | **TOTAL** | 8,328 | | $126,729.60 | $12,672.96 | $114,056.64 |

| ID | COMPANY NAME | 338/339 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 430,000 | $3.00 | | | |
| 1 | Gladpeer Garment Factory Cambodia Co Ltd | 3,500 | $8.40 | $29,400.00 | $2,940.00 | $26,460.00 |
| 2 | Franco Knitting Garment Factory Ltd | 5,000 | $8.00 | $40,000.00 | $4,000.00 | $36,000.00 |
| 3 | South Bay Enterprises Co Ltd | 5,000 | $8.00 | $40,000.00 | $4,000.00 | $36,000.00 |
| 4 | Ming Hoi Cambodia Garment MFG Ltd | 20,000 | $8.00 | $160,000.00 | $16,000.00 | $144,000.00 |
| 5 | Yashin Industries Co Ltd | 5,000 | $7.60 | $38,000.00 | $3,800.00 | $34,200.00 |
| 6 | Fame Cambodia Knitting Garment Factory Ltd | 5,000 | $7.40 | $37,000.00 | $3,700.00 | $33,300.00 |
| 7 | Yung Wah Industrial Cambodia Co Ltd | 80,000 | $7.40 | $592,000.00 | $59,200.00 | $532,800.00 |
| 8 | Fortune Garment & Woolen Knitting Factory | 5,000 | $7.40 | $37,000.00 | $3,700.00 | $33,300.00 |
| 9 | Loyal Cambodia Co Ltd | 5,000 | $7.20 | $36,000.00 | $3,600.00 | $32,400.00 |
| 10 | Maurea Garments Corp | 2,000 | $7.20 | $14,400.00 | $1,440.00 | $12,960.00 |
| 11 | Top World Garment Co Ltd | 5,000 | $7.00 | $35,000.00 | $3,500.00 | $31,500.00 |
| 12 | Goldfame Enterprises Knitting Co Ltd | 60,000 | $7.00 | $420,000.00 | $42,000.00 | $378,000.00 |
| 13 | Cheer View Textile Co Ltd | 20,000 | $6.60 | $132,000.00 | $13,200.00 | $118,800.00 |
| 14 | June Textiles Co Ltd | 199,524 | $6.20 | $1,237,048.80 | $123,704.88 | $1,113,343.92 |
| 15 | San Lei Fung Garment & Woolen Knitting Factory | 9,976 | $6.20 | $61,851.20 | $6,185.12 | $55,666.08 |
| | **TOTAL** | 430,000 | | $2,909,700.00 | $290,970.00 | $2,618,730.00 |

| ID | COMPANY NAME | 340/640 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 235,000 | $1.00 | | | |
| 1 | Ocean Garment Co Ltd | 5,500 | $1.20 | $6,600.00 | $660.00 | $5,940.00 |
| 2 | MSI Garment Cambodia Co Ltd | 100,000 | $1.00 | $100,000.00 | $10,000.00 | $90,000.00 |
| 3 | Eternal Way Cambodia Co Ltd | 25,000 | $1.00 | $25,000.00 | $2,500.00 | $22,500.00 |
| | **TOTAL** | 130,500 | | $131,600.00 | $13,160.00 | $118,440.00 |

ANNEX - A

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE

1:03 PM, 06/06/2002

| ID | COMPANY NAME | 345 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 9,748 | $3.00 | | | |
| 1 | Fortune Garment & Woolen Knitting Factory | 3,000 | $9.00 | $27,000.00 | $2,700.00 | $24,300.00 |
| 2 | Goldfame Enterprises Knitting Co Ltd | 4,000 | $7.20 | $28,800.00 | $2,880.00 | $25,920.00 |
| 3 | San Lei Fung Garment & Woolen Knitting Factory | 2,748 | $7.00 | $19,236.00 | $1,923.60 | $17,312.40 |
| | **TOTAL** | **9,748** | | **$75,036.00** | **$7,503.60** | **$67,532.40** |

| ID | COMPANY NAME | 347/348/647/648 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 300,988 | $3.00 | | | |
| 1 | Gladpeer Garment Factory Cambodia Co Ltd | 400 | $10.40 | $4,160.00 | $416.00 | $3,744.00 |
| 2 | Tai Yang Enterprises Co Ltd | 25,000 | $10.00 | $250,000.00 | $25,000.00 | $225,000.00 |
| 3 | Sharp Casual Co Ltd | 30,000 | $9.40 | $282,000.00 | $28,200.00 | $253,800.00 |
| 4 | Golden Jet Cambodia Garment Ltd | 7,000 | $9.00 | $63,000.00 | $6,300.00 | $56,700.00 |
| 5 | Wearwel Cambodia Ltd | 10,000 | $8.40 | $84,000.00 | $8,400.00 | $75,600.00 |
| 6 | Kin Tai Garment Co Ltd | 30,000 | $8.40 | $252,000.00 | $25,200.00 | $226,800.00 |
| 7 | Roo Hsing Garment Co Ltd | 80,000 | $8.20 | $656,000.00 | $65,600.00 | $590,400.00 |
| 8 | Kennetex Int'l Cambodia Co Ltd | 34,000 | $7.60 | $258,400.00 | $25,840.00 | $232,560.00 |
| 9 | Ospinter Garments MFG Cambodia Ltd | 3,500 | $7.40 | $25,900.00 | $2,590.00 | $23,310.00 |
| 10 | In Fong Cambodia Garment Co Ltd | 800 | $7.40 | $5,920.00 | $592.00 | $5,328.00 |
| 11 | Emperor Garment Industry Co Ltd | 20,000 | $7.40 | $148,000.00 | $14,800.00 | $133,200.00 |
| 12 | Loyal Cambodia Co Ltd | 16,000 | $7.40 | $118,400.00 | $11,840.00 | $106,560.00 |
| 13 | June Textiles Co Ltd | 23,811 | $7.20 | $171,439.20 | $17,143.92 | $154,295.28 |
| 14 | Eternity Apparel Garment Co Ltd | 7,619 | $7.20 | $54,856.80 | $5,485.68 | $49,371.12 |
| 15 | Top World Garment Co Ltd | 4,762 | $7.20 | $34,286.40 | $3,428.64 | $30,857.76 |
| 16 | Maurea Garments Corp | 8,096 | $7.20 | $58,291.20 | $5,829.12 | $52,462.08 |
| | **TOTAL** | **300,988** | | **$2,466,653.60** | **$246,665.36** | **$2,219,988.24** |

| ID | COMPANY NAME | 352/652 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 35,486 | $0.50 | | | |
| 1 | Wilson Garment Cambodia Co Ltd | 24,223 | $0.70 | $16,956.10 | $1,695.61 | $15,260.49 |
| 2 | Manhattan Textiles & Garment Corp | 2,048 | $0.70 | $1,433.60 | $143.36 | $1,290.24 |
| 3 | PYL Cambodia Co Ltd | 3,413 | $0.70 | $2,389.10 | $238.91 | $2,150.19 |
| 4 | Golden Jet Cambodia Garment Ltd | 5,802 | $0.70 | $4,061.40 | $406.14 | $3,655.26 |
| | **TOTAL** | **35,486** | | **$24,840.20** | **$2,484.02** | **$22,356.18** |

| ID | COMPANY NAME | 438 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 2,573 | $2.00 | | | |
| 1 | Universal Apparel Cambodia Co Ltd | 500 | $7.40 | $3,700.00 | $370.00 | $3,330.00 |
| 2 | Goldfame Enterprises Knitting Co Ltd | 2,073 | $4.00 | $8,292.00 | $829.20 | $7,462.80 |
| | **TOTAL** | **2,573** | | **$11,992.00** | **$1,199.20** | **$10,792.80** |

**ANNEX - A**

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE

1:03 PM, 06/06/2002

| ID | COMPANY NAME | 638/639 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **84,000** | **$1.00** | | | |
| 1 | Yung Wah Industrial Cambodia Co Ltd | 32,000 | $3.00 | $96,000.00 | $9,600.00 | $86,400.00 |
| 2 | Archid Garment Factory Cambodia Ltd | 2,000 | $1.80 | $3,600.00 | $360.00 | $3,240.00 |
| 3 | Best Honour Int'l Garment Ltd | 2,500 | $1.80 | $4,500.00 | $450.00 | $4,050.00 |
| 4 | Yubin Services Co Ltd | 20,000 | $1.60 | $32,000.00 | $3,200.00 | $28,800.00 |
| 5 | Tai Yar Garment Industries Ltd | 20,000 | $1.60 | $32,000.00 | $3,200.00 | $28,800.00 |
| 6 | PYL Cambodia Co Ltd | 1,250 | $1.40 | $1,750.00 | $175.00 | $1,575.00 |
| 7 | Quality Textiles Co Ltd | 1,250 | $1.40 | $1,750.00 | $175.00 | $1,575.00 |
| 8 | Vinstar Garment Industry Co Ltd | 5,000 | $1.40 | $7,000.00 | $700.00 | $6,300.00 |
| **TOTAL** | | **84,000** | | **$178,600.00** | **$17,860.00** | **$160,740.00** |

| ID | COMPANY NAME | 645/646 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **52,160** | **$0.50** | | | |
| 1 | D.A Corporation., Ltd | 5,000 | $0.70 | $3,500.00 | $350.00 | $3,150.00 |
| 2 | Mighti Spectra Knitting Factory Co Ltd | 400 | $0.50 | $200.00 | $20.00 | $180.00 |
| **TOTAL** | | **5,400** | | **$3,700.00** | **$370.00** | **$3,330.00** |